**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...៥៧...អនក្រ.បក**

**អនុក្រឹត្យ**

**ស្ដីពី**

**ការធ្វើអនុបយោគ ផ្ទៃដីស្ថិតនៅសង្កាត់ព្រែកតាសេក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និង នៅឃុំសំបួរមាស ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្ដាល**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦ /០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-យោងលិខិតលេខ ១២៥៧ សជណ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៧ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី

-យោងលិខិតលេខ ៤៥៥៣/០៧ កអក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-លិខិតលេខ ៣៥៧ ដនស-អវទ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៨ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-យោងលិខិតលេខ ៤៣៦ ដនស/អវទ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងរៀបចំដែនដី

នគរូបនីយកម្ម និង សំណង់

-យោងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីសាធារណៈរបស់រដ្ឋទំហំ៨០០.០០៩៥ ( ប្រាំបីរយហិកតា និង ហាសិបប្រាំម៉ែត្រក្រឡា) ដែលស្ថិតនៅសង្កាត់ព្រែកតាសេក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និង នៅឃុំសំបួរមាស ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ក្នុងតំបន់សហគមន៍នេសាទ សំរាប់ការសាងសង់ផ្លូវពីគល់ស្ពានថ្មីតភ្ជាប់ឆ្ពោះទៅផ្លូវជាតិលេខ៦ អា តាមនិយាមកា របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដូចមានចែងក្នុងលិខិតលេខ ៣៥៧ ដនស/អវទ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៨ មកជាដីឯកជនរបស់រដ្ឋ ។

**មាត្រា ២.-**

ត្រូវបានប្រគល់សិទ្ធិជូនក្រុមហ៊ុន **ឈិង.ចាំង.គី គ្រុប** កាន់កាប់ ធ្វើការអភិវឌ្ឍន៍គំរោងវិនិយោគលើផ្ទៃដី ដូចមានចែងក្នុង**មាត្រា ១** ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ អភិបាលខេត្តកណ្តាល និង ក្រុមហ៊ុន **ឈិង.ចាំង.គី គ្រុប** ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋាន រដ្ឋសភា

-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-អគ្គលេខាធិការ រាជរដ្ឋាភិបាល

-ដូចមាត្រា ៤

-ឯកសារ-កាលប្បវត្តិ